ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 02-Oct-2015, 09:14
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour supreme

សំណុំរឿងលេខៈ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

**នៅចំពោះមុខៈ**

**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុនីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារៈ** **ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៥**
**ភាសាដើមៈ** **ខ្មែរ/អង់គ្លេស**
**ចំណាត់ថ្នាក់ឯកសារៈ** **សាធារណៈ**

# សេចក្តីសម្រេចស្នើឱ្យដាក់សារណា

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីជនជាប់ចោទ នួន ជា**
សុន អរុណ
Victor KOPPE

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

01151678



**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("**អង្គជំនុំជម្រះតុលាការកំពូល**" និង"**អ.វ.ត.ក**"),

**រំលឹកថា** "សេចក្តីសម្រេចបណ្តោះអាសន្នលើកទីបីស្តីពីកិច្ចសើបសួរបន្ថែម" របស់**ចៅក្រមតំណាង** ("សេចក្តីសម្រេចបណ្តោះអាសន្នលើកទីបី")[1] ដែលក្នុងនោះ Robert Thomas Fitzgibbon LEMKIN ("Robert Lemkin") ជាអ្នកផលិតភាពយន្ត ត្រូវបានស្នើឱ្យផ្តល់"ប្រតិចារិក និងសៀវភៅកំណត់ហេតុទាំងអស់" ទាក់ទងនឹងការស្តាប់ចម្លើយដែលគាត់បានធ្វើឡើងជាមួយបុគ្គលបួនរូប ដូចបានរៀបរាប់នៅក្នុងកំណត់ហេតុដែលគាត់ប្រគល់ជូនកន្លងមក ("បុគ្គលបួនរូប")[2],

**កត់សម្គាល់ឃើញថា** នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានទទួលឯកសារជា PDF ចំនួន ២០ ច្បាប់តាមរយៈអ៊ីមែលពី Robert Lemkin[3] ហើយ ឆ្លៀតឱ្យកាសនេះ អង្គជំនុំជម្រះតុលាការកំពូល សូមថ្លែងអំណរគុណចំពោះការសហការក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរបន្ថែមនេះ និងថា ឯកសារទាំងនេះ ទំនងជាមានប្រតិចារិកនៃការស្តាប់ចម្លើយមួយចំនួនដែលបានធ្វើឡើងជាមួយបុគ្គលទាំងបួនរូបនោះ ("ប្រតិចារិក") ដែលនឹងត្រូវភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងសេចក្តីសម្រេចនេះ[4],

---

[1] ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥ ឯកសារលេខ F2/4/3/3/5។ *សូមមើលផងដែរ* សេចក្តីសម្រេចអនុលោមតាមវិធាន ៣៩(២)(ក) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៥ ឯកសារលេខ F2/4/3/3/5/1។

[2] សេចក្តីសម្រេចបណ្តោះអាសន្នទីបីទំព័រ ៥។ កំណត់ហេតុដែលដាក់ដោយ Robert Lemkin អាចរកបាននៅក្នុងសំណុំរឿង ០០២ ជាឧបសម្ព័ន្ធ-កំណត់ហេតុរបស់ Robert Lemkin's ស្តីពីរបៀបវារៈនយោបាយរបស់ រួស ញឹម (សម្ងាត់) ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F2/4/3/3.1។

[3] របាយការណ៍របស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជាការឆ្លើយតបទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ឯកសារលេខ F2/4/3/3/5/1 ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារលេខ F2/4/3/3/6.1។

[4] ប្រតិចារិកនៃការស្តាប់ចម្លើយដែលបានផ្តល់ជូនដោយ Robert Lemkin (សម្ងាត់) ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ F2/4/3/3/6.2។ អង្គជំនុំជម្រះតុលាការកំពូលជូនដំណឹងភាគីថា ឯកសារមួយច្បាប់ដែល Robert Lemkin ប្រគល់ជូនដោយចៃដន្យ មានឈ្មោះបុគ្គលដែលសំដៅលើ"W4" និងឯកសារដទៃទៀតរួមមានអត្ថបទសម្ងាត់ ពីព្រោះអត្ថបទនេះ អាចត្រូវបានធ្វើការសន្និដានចេញពីចន្លោះនានានៅក្នុងការស្តាប់ចម្លើយ និងកន្លែងបានដកអក្សរចេញ។ អង្គជំនុំជម្រះសម្រេចកោសលុបឈ្មោះ W4 រហូតដល់អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានធ្វើកវាយតម្លៃលើហានិភ័យទាក់ទងនឹងសេចក្តីសម្រេចបណ្តោះអាសន្នទីបី និងតាមការសន្មតថា អត្ថបទសម្ងាត់នេះ ពុំអាចបង្ហាញបាន ដែលត្រូវតែដកចេញពីពីឯកសារ។ អង្គជំនុំជម្រះសង្កេត

**កត់សម្គាល់ឃើញ**ថា ប្រតិចារិកទាំងនេះ ដូចគ្នាទៅនឹងសំណើភាគច្រើនរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម គឺជាប់ពាក់ព័ន្ធក្នុងផ្នែកជាច្រើនទៅនឹងជម្លោះដែលបានអះអាងថា បានកើតឡើងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងសកម្មភាពនានា ដើម្បីផ្តួលរំលំការដឹកនាំរបស់ ប៉ុល ពត និង នួន ជា នៃបក្សកុម្មុយនីស្តកម្ពុជា,

**កត់សម្គាល់**លើអំណះអំណាងរបស់ នួន ជា ដែលថា ជម្លោះនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងសកម្មភាពនានា ដើម្បីផ្តួលរំលំថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា បានបង្ហាញថា មជ្ឈិមបក្ស"បានអនុវត្តការគ្រប់គ្រងប្រសិទ្ធិភាពតិចតួចតែប៉ុណ្ណោះ ទៅលើកម្មាភិបាលពាសពេញឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជា"[5] និងថា កម្មាភិបាលថ្នាក់ក្រោម ជាពិសេស លេខាភូមិភាគ "បានអនុវត្តសិទ្ធិអំណាចឯករាជ្យជាច្រើន"[6] និង ដោយមានការគាំទ្រពីវៀតណាម បានព្យាយាមបង្កការបះបោរប្រឆាំងនឹងមជ្ឈិមបក្ស ដើម្បីដណ្តើមអំណាច[7] និងថា ហេតុដូច្នេះ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹង *ក្នុងចំណោមនោះ* រចនាសម្ព័ន្ធជាឋានានុក្រមយ៉ាងចង្អៀតរបស់បក្សកុម្មុយនីស្តកម្ពុជា និងការអនុវត្តតាមយ៉ាងហ្មត់ចត់របស់កម្មាភិបាលថ្នាក់ក្រោម នូវការណែនាំដែលចេញពីថ្នាក់លើរបស់បក្សកុម្មុយនីស្តកម្ពុជានៅភ្នំពេញ រួមមាន នួន ជា ផងនោះ មានកំហុស និងថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើសេចក្តីសន្និដ្ឋានពុំត្រឹមត្រូវថា "ចារីនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នេះ បានអនុត្តតាមគោលនយោបាយនិងការណែនាំ

---

ឃើញថា ខ្លឹមសារនៃអត្ថបទនេះ ពុំទំនងជាមានការជាប់ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ព័ត៌មានគួរជឿជាក់បានរបស់បុគ្គលបួនរូប ឬក៏មានព័ត៌មានដែលបានដាក់នៅក្នុងសំណុំរឿងឡើយ។

[5] សំណើទីប្រាំមួយរបស់ នួន ជា សុំពិចារណា និងទទួលយកភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១, ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារលេខ F2/8 ("សំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម") កថាខណ្ឌ ១០។

[6] សំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម កថាខណ្ឌ ១០។

[7] *សូមមើលឧ.* សំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម កថាខណ្ឌ ២ ដល់ ១៣ និង ១៥១ ដល់ ១៥៤។ សំណើទីប្រាំរបស់ នួន ជាសុំពិចារណា និងទទួលយកភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារលេខ F2/7 កថាខណ្ឌ ១ ដល់២ និង ៥២ ដល់ ៥៧។ បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១, ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F16 ("សារណាបណ្តឹងសាទុក្ខ") កថាខណ្ឌ ២២៥ ដល់ ២៤៩។

របស់បក្ស"[8] និងថា សហឧក្រិដ្ឋកម្មរួម បានដាក់បញ្ចូលរូបគាត់ ជាមួយនឹងបុគ្គលដែល នៅក្នុងសារណា របស់ នួន ជា គឺជាបុគ្គលតែមួយដែលប៉ុនប៉ងធ្វើរដ្ឋប្រហារប្រឆាំងនឹងរូបគាត់[9],

**ពិចារណាឃើញ**ថា សារណារបស់ នួន ជា នៅមុខអង្គជំនុំជម្រះសាលាដំបូង ពុំបានលើកឡើងជាក់លាក់ អំពីការបញ្ចូលនូវជម្លោះដែលកើតមាននៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងសកម្មភាពនានា ក្នុងការផ្តួលរំលំ ការដឹកនាំរបស់ ប៉ុល ពត និង នួន ជា នៃបក្សកុម្មុយនីស្តកម្ពុជា លើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជា លក្ខណៈបុគ្គលរបស់គាត់ឡើយ ដូចជាលើបញ្ហា ថាតើ បានធ្វើឱ្យប៉ះពាល់លើសម្អាងហេតុណាខ្លះរបស់អង្គ ជំនុំជម្រះសាលាដំបូង និងមូលហេតុអ្វីខ្លះ ប្រសិនបើសម្អាងហេតុនេះ ត្រូវបានបដិសេធចោទនៅលើបណ្តឹង សាទុក្ខ ហើយ ថាតើ អាចមោឃៈពិរុទ្ធភាពរបស់ នួន ជា ទាំងមូល ឬផ្នែកខ្លះ ដែរ ឬយ៉ាងណា ពាក់ព័ន្ធនឹង ឧក្រិដ្ឋកម្មជាក់លាក់ និងទម្រង់នៃការទទួលខុសត្រូវ,

**ពិចារណាឃើញ**ថា ដោយផ្អែកលើសារៈសំខាន់នៃអំណះអំណាងនេះចំពោះបណ្តឹងសាទុក្ខរបស់ នួន ជា ដើម្បីជាប្រយោជន៍យុត្តិធម៌ នួន ជា ត្រូវបានផ្តល់ឱកាសបន្ថែមទៀត ក្នុងការបញ្ជាក់សារណារបស់ខ្លួនលើ បញ្ហានេះ,

## អាស្រ័យហេតុនេះសម្រេចៈ

**ស្នើឱ្យ**ភាគី ដាក់សារណាតបជាលាយលក្ខណ៍អក្សរយ៉ាងយូរត្រឹមថ្ងៃ សុក្រ ទី ០៩ ខែ តុលា ឆ្នាំ ២០១៥ វេលាម៉ោង ១០:០០ ព្រឹក លើបញ្ហាថាតើ ប្រតិចារិកនេះ គប្បីទទួលយកជាភស្តុតាងទាំងមូល ឬផ្នែកខ្លះ,

**ស្នើឱ្យ** នួន ជា នៅក្នុងសារណាដដែល បញ្ជាក់ឱ្យបានជាក់លាក់លើការបញ្ចូលនូវជម្លោះដែលបានកើត ឡើងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងសកម្មភាពនានា ក្នុងការផ្តួលរំលំការដឹកនាំរបស់ ប៉ុល ពត និង នួន ជា នៃបក្សកុម្មុយនីស្តកម្ពុជា (មានដូចជា ការប្រជុំសង្ងាត់ ការធ្វើពើជាបង្កសង្គ្រាមជាមួយប្រទេសថៃ និងការ លាក់ទុកស្បៀង អាវុធ និងសម្ភារៈផ្គត់ផ្គង់ផ្សេងៗ ក្នុងការត្រៀមរៀបចំដើម្បីបះបោរប្រឆាំងនឹងមជ្ឈិម បក្ស) លើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់គាត់ ដូចជាលើបញ្ហា ថាតើ បានធ្វើឱ្យ ប៉ះពាល់លើសម្អាងហេតុណាខ្លះរបស់អង្គជំនុំជម្រះសាលាដំបូង និងមូលហេតុអ្វីខ្លះ ប្រសិនបើសម្អាងហេតុ នេះ ត្រូវបានបដិសេធចោទនៅលើបណ្តឹងសាទុក្ខ ហើយ ថាតើ អាចមោឃៈពិរុទ្ធភាពរបស់ នួន ជា ទាំង មូល ឬផ្នែកខ្លះ ដែរ ឬយ៉ាងណា ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មជាក់លាក់ និងទម្រង់នៃការទទួលខុសត្រូវ,

---

[8] សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២២៦។

[9] សំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម កថាខណ្ឌ ១៥១។

**ស្នើឱ្យ**ភាគី ដាក់សារណាតបទៅនឹងសារណារបស់ នួន ជា យ៉ាងយូរត្រឹមថ្ងៃ សុក្រ ទី ១៦ ខែ តុលា ឆ្នាំ ២០១៥,

**ណែនាំ**ថា ភាគីពុំអនុញ្ញាតឱ្យដាក់ចម្លើយតបឡើយ,

**ណែនាំ**ថា ភាគី ត្រូវដាក់សារណា ជាភាសាខ្មែរ និងអង់គ្លេស ឬបារាំង ជាកំហិតដោយគ្មានករណីលើកលែងឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រឹម**